# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង
## រវាង
## រោងចក្រ អរិន មេនូហ្វេកធើរីង ( ខ្មែរ )
## និង
## តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានប្រចាំ
## រោងចក្រ អរិន មេនូហ្វេកធើរីង ( ខ្មែរ )

## ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង០៩និង០០នាទីព្រឹកនៅក្នុងរោងចក្រ **អរិន មេនូហ្វេកធើរីង (ខ្មែរ)** មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិត សហជីពមូលដ្ឋានប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងបច្ចុប្បន្នប្រឈមមុខខ្លាំងជាមួយបញ្ហាខ្វះអ្នកបញ្ជាទិញដែលចំណុចនេះហើយធ្វើអោយផលិតកម្មមួយចំនួនធំមិនមានការងារធ្វើ តម្រូវអោយមានការព្យួរការងារ។ហេតុដូចនេះក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំងអស់រយៈពេល ០២ខែ ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣ ចំនួន ៨២១នាក់ ស្រី ៦៨០នាក់ ។ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករនិយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុនតាមលក្ខខណ្ឌដូចខាងក្រោម៖

- ចំនួន ២០ដុល្លារអាមេរិក ពីរាជរដ្ឋាភិបាល និងចំនួន ១៥ដុល្លារអាមេរិក ពីនិយោជក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១៤ថ្ងៃ។
- ចំនួន ៤០ដុល្លារអាមេរិក ពីរាជរដ្ឋាភិបាល និងចំនួន ៣០ដុល្លារអាមេរិក ពីនិយោជក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ ដល់ ១ខែ។
- កាលបរិច្ឆេទបើកប្រាក់ ព្យួរការងារសម្រាប់ខែមេសា នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ និងប្រាក់ព្យួរសម្រាប់ខែឧសភា បើកនៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣។

អង្គប្រជុំបានចប់វេលាម៉ោង ១១ និង០០នាទីព្រឹក នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងខាងមានភាពស្និទ្ធស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួលខុសត្រូវ និង សហការគ្នាយ៉ាងរលូន ។

កំចាយមារ.ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣

**តំណាងកម្មករ និង តំណាងសហជីព** | **នាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
អរិន មេនូហ្វេកធើរីង (ខ្មែរ)
ORANGE MANUFACTURING (KHMER) Co., Ltd.
KINGDOM OF CAMBODIA

កុវី តាមុល　　ស៊ុយ ស្រីភាព　　ទាំង ចាន់ឡើន　　ឡាំ ឧស្សីទាវ

ហ៊ីម ម៉ើ　　វ៉ែម ម៉ី　　ឆេង ណារ　　ឆា ល័ក្ខ

ពុធ ប៊ូនី　　ស៊ា ឆានី　　ម៉ា សំបា　　សុខ តាម៉ម

ពៅ ស្រីកញ្ញា